# របាយការណ៍ស្តីពីការចុះពិនិត្យតាមដានការងារផ្តល់សេវាបង្ការនិងថែទាំព្យាបាល
# ការបង្ករោគតាមការរួមភេទនិងប្រដាប់បន្តពូជ ចំពោះស្ត្រីធ្វើការនៅសេវាកំសាន្ត
# ខេត្តមណ្ឌលគិរី

## ទីកន្លែងៈ

- ការិយាល័យអេដស៍-កាមរោគខេត្ត
- ការិយាល័យរបស់អង្គការ RHAC ប្រចាំខេត្តមណ្ឌលគិរី
- មណ្ឌលសុខភាពសៃនមនោរម្យ/មន្ទីរពេទ្យបង្អែកខេត្តមណ្ឌលគិរី

## កាលបរិច្ឆេទៈ

- ពីថ្ងៃទី ៣0 ខែសីហា ដល់ ថ្ងៃទី ៣ ខែកញ្ញា ឆ្នាំ២០១០ ។

## មន្ត្រីចុះបេសកកម្មៈ

- លោកវេជ្ជ. ផល សាណូ ប្រធានផ្នែកគ្រប់គ្រងព្យាបាលជំងឺបង្កតាមការរួមភេទ និងប្រដាប់បន្តពូជ
- លោកវេជ្ជ. នេត សាន្តសុទ្ធី ប្រធានផ្នែកប្រាស្រ័យទាក់ទងដើម្បីផ្លាស់ប្តូរការប្រព្រឹត្ត
- លោកវេជ្ជ. ហួត គន្ធាភិរម្យ អនុប្រធានផ្នែកប្រាស្រ័យទាក់ទងដើម្បីផ្លាស់ប្តូរការប្រព្រឹត្ត
- លោកស្រីវេជ្ជ. លឹម សុវណ្ណបុប្ផា មន្ត្រីផ្នែកគ្រប់គ្រងព្យាបាលជំងឺបង្កតាមការរួមភេទ និងប្រដាប់បន្តពូជ
- លោក ធុយ ព័រ អ្នកបើកបរ។

## គោលបំណងៈ

១- ពិនិត្យតាមដាន និងផ្តល់ជំនួយលើផ្នែកបច្ចេកទេសដល់បុគ្គលិកកម្មវិធីអេដស៍-កាមរោគ, បុគ្គលិកអង្គការក្រៅរដ្ឋាភិបាលដែលជាដៃគូក្នុងការបង្ការនិងការថែទាំព្យាបាលបន្តក្នុងខេត្តមណ្ឌលគិរី ក៏ដូចជាការពង្រឹងការបញ្ជូនក្រុមស្ត្រីធ្វើការនៅសេវាកំសាន្តទៅកាន់គ្លីនិកកាមរោគ ។

២- ដោះស្រាយនូវបញ្ហានិងសំណូមពរមួយចំនួនដែលមាននៅក្នុងខេត្តមណ្ឌលគិរី ទៅតាមលទ្ធភាពដែលអាចធ្វើបាន ព្រមទាំងស្វែងរកតំរូវការបន្ថែមដើម្បីជំរុញអោយសេវាថែទាំកាមរោគដំណើរការបានល្អ និងមានប្រសិទ្ធិភាព។

## **សកម្មភាពការងារ**

- ក្រុមពិនិត្យតាមដានការងារនៃមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ បានជំរាបជូន អំពីគោលបំណងនៃបេសកកម្មជូនលោក គុជ វណ្ណា ប្រធានការិយាល័យរដ្ឋបាលនៃមន្ទីរសុខាភិបាលខេត្តមណ្ឌលគីរី និងជាប្រធានកម្មវិធីប្រយុទ្ធនឹងជំងឺអេដស៍-កាមរោគខេត្ត និងលោក អ៊ី គង់ អនុប្រធាន កម្មវិធីប្រយុទ្ធនឹងជំងឺអេដស៍-កាមរោគខេត្ត អំពីការចុះ ពិនិត្យតាមដានការងារអប់រំផ្ទាល់មិត្តអប់រំមិត្ត និងការបញ្ជូនស្ត្រីធ្វើការនៅសេវាកំសាន្តអោយមកទទួលសេវាថែទាំជំងឺកាមរោគ។ បន្ទាប់ពីបានជួបពិភាក្សាជាមួយគ្នារួចមក ក្រុមអភិបាលការងារបានចុះបំពេញការងារ ទៅតាមកម្មវិធី ដែលបានគ្រោងទុក។
- **ការចុះពិនិត្យ និងជួបពិភាក្សាការងារផ្ទាល់ជាមួយមន្ត្រីអង្គការមិនមែនរដ្ឋាភិបាលជាដៃគូ :**
    - ការិយាល័យរបស់អង្គការ RHAC ប្រចាំខេត្តមណ្ឌលគីរី

## **លទ្ធផលការងារ**

**ស្ថានភាពមណ្ឌលសុខភាពសែនមនោរម្យ :**



- មណ្ឌលសុខភាពនេះមានទីតាំងនៅក្នុងមន្ទីរពេទ្យបង្អែកខេត្តមណ្ឌលគីរី សំរាប់ផ្តល់សេវាពិនិត្យ និងព្យាបាលជំងឺក្រៅ ជូនដល់អតិថិជនគ្រប់ប្រភេទ ដែលមកពិគ្រោះ និងពិនិត្យជំងឺ។
- សេវាថែទាំព្យាបាលជំងឺកាមរោគត្រូវបានដាក់បញ្ចូលទៅក្នុងមណ្ឌលសុខភាពនេះ សំរាប់ពិនត្យ និងព្យាបាលជំងឺកាមរោគជូនដល់ប្រជាជនទូទៅ និងក្រុមស្រ្តីធ្វើការនៅសេវាកំសាន្ត។
- សេវាថែទាំជំងឺកាមរោគនៅមណ្ឌលសុខភាពនេះ ពុំទាន់បានរៀបចំអោយទៅជាគ្លីនិកសុខភាពគ្រួសារ ដែលមានមន្ទីរពិសោធន៏កាមរោគនៅឡើយទេ ដោយសារស្រ្តីធ្វើការនៅសេវាកំសាន្តទើបតែមានចំនួនកើនឡើង នៅពេលដែលផ្លូវតមនាគមន៍ ទើបនឹងសាងសង់រួចរាល់នៅពេលថ្មីៗនេះទេ។
- សេវាថែទាំជំងឺកាមរោគត្រូវបានផ្តល់នៅក្នុងបន្ទប់មួយដែលសំរាប់ពិនិត្យ និងព្យាបាលរោគស្រ្តីដែលមានសំភារៈបច្ចេកទេស ដូចជា គ្រែពិនិត្យរោគស្រ្តី និងសំភារៈពិនិត្យទ្វារមាសស្រ្តីផ្សេងៗទៀត របស់មណ្ឌលសុខភាព។
- បន្ទប់ផ្តល់សេវានេះស្ថិតនៅជាប់នឹងបន្ទប់ផ្តល់សេវាធ្វើតេស្តឈាមរកមេរោគអេដស៏ និងបន្ទប់ផ្តល់សេវាបង្ការការចំលងមេរោគអេដស៏ពីម្តាយទៅកូន។





- គ្រប់អតិថិជនទាំងអស់ដែលមកទទួលសេវាថែទាំជំងឺកាមរោគនៅមណ្ឌលសុខភាពនេះ រួមទាំងស្ត្រីធ្វើការនៅសេវាកំសាន្ត ត្រូវបង់តំលៃសេវាហិរញ្ញប្រទានសំរាប់ទ្រទ្រង់មណ្ឌលសុខភាព ក្នុងតំលៃ ២០០០ រៀល សំរាប់ការពិនិត្យ និងព្យាបាលជំងឺមួយលើក។ អង្គការ RHAC ជាអ្នកបង់តំលៃសេវានេះជូនស្ត្រីធ្វើការនៅសេវាកំសាន្ត ដែលមន្ត្រីកម្មវិធីអប់រំផ្ទាល់/មិត្តអប់រំមិត្តរបស់អង្គការ RHAC បានបញ្ជូនទៅពិនិត្យសុខភាព។

**ស្ថានភាពស្ត្រីធ្វើការនៅសេវាកំសាន្តក្នុងខេត្តមណ្ឌលគិរី :**

- ខេត្តមណ្ឌលគិរី មានស្រុករដ្ឋបាលចំនួន ៥ ដែលរួមគ្នាជាស្រុកប្រតិបត្តិចំនួន ១, មន្ទីពេទ្យបង្អែកចំនួន១, មណ្ឌលសុខភាពចំនួន ៧ និងប៉ុស្តសុខភាពចំនួន ១៨។
- សេវាកំសាន្តមាននៅ ស្រុកសែនមនោរម្យ, ស្រុកពេជជ្រេដា និង ស្រុកកែវសីម៉ា (មេម៉ង់)។
- មានអង្គការមិនមែនរដ្ឋាភិបាលតែមួយប៉ុណ្ណោះ គឺ អង្គការ RHAC ដែលធ្វើការអប់រំផ្ទាល់ដល់ស្ត្រីធ្វើការនៅសេវាកំសាន្ត និងបញ្ជូនអោយស្ត្រីទាំងនោះមកទទួលសេវាថែទាំសុខភាពនៅមណ្ឌលសុខភាព ដោយប្រើប្រាស់ថវិការគំរោងមូលនិធិសកលជុំទី ៥ ដំណាក់កាលទី ១ និងទី ២។

- តាមរបាយការណ៍របស់លោក ជឿន ចាន់ថុល ប្រធានមណ្ឌលអង្គការ RHAC ប្រចាំខេត្តមណ្ឌលគីរី និងលោក ចិត្រ សុឃីម ជំនួយការអង្គការ RHAC ទទួលបន្ទុកក្រុមស្ត្រីធ្វើការនៅសេវាកំសាន្ត បានអោយដឹងថា :
  - ស្រុកសែនមនោរម្យមានស្ត្រីធ្វើការនៅសេវាកំសាន្ត សរុបចំនួន ៩៤ នាក់ :
    - ខារ៉ាអូខេ ចំនួន ៩ កន្លែង ដែលមានស្ត្រីធ្វើការចំនួន ៨0 នាក់
    - ភោជនីយដ្ឋាន និងអាហារដ្ឋាន ចំនួន ៣ ដែលមានស្ត្រីធ្វើការចំនួន ១១ នាក់
    - បៀហ្គាខ្មែន ចំនួន ១ កន្លែង ដែលមានស្ត្រីចំនួន ៣ នាក់
  - ស្រុកកែវសីម៉ាមានស្ត្រីធ្វើការនៅសេវាកំសាន្ត សរុបចំនួន ១៥ នាក់ :
    - ឃុំ ស្រែខ្ទុំ មានខារ៉ាអូខេ ១ កន្លែង មានស្ត្រីធ្វើការចំនួន ៤ នាក់
    - ឃុំ មេម៉ង់ មានខារ៉ាអូខេ ៣ កន្លែង មានស្ត្រីធ្វើការចំនួន ១១ នាក់
  - ស្រុក ពេជ្រជ្រដា មានសេវាកំសាន្ត ២ កន្លែង ប៉ុន្តែសព្វថ្ងៃនេះគ្មានស្ត្រីធ្វើការនៅទីនោះទេ។
- អង្គការ RHAC មាន PF ចំនួន ១ រូប និងមាន PE ចំនួន ២៣ រូបដែលត្រូវបានបណ្តុះបណ្តាលបំប៉នរៀងរាល់ ៦ ខែម្តង ដើម្បីពង្រឹងចំណេះដឹងនៃការអប់រំស្តីអំពីការបង្ការការចំលងមេរោគអេដស៍ និងការថែទាំសុខភាពបន្តពូជ។
- ដោយសារតែមណ្ឌលសុខភាពសែនមនោរម្យ អាចផ្តល់សេវាថែទាំជំងឺកាមរោគដោយពឹងផ្អែកលើចង្កោមរោគសញ្ញា ដូច្នេះ ការបញ្ជូនស្ត្រីធ្វើការនៅសេវាកំសាន្តទៅមណ្ឌលសុខភាពអាចធ្វើបានតែស្ត្រីដែលមានរោគសញ្ញាតែប៉ុណ្ណោះ។
- មានស្ត្រីប្រមាណជា ២0-៣0 នាក់តែប៉ុណ្ណោះ ដែលត្រូវបានបញ្ជូនទៅពិនិត្យសុខភាពនៅមណ្ឌលសុខភាពរៀងរាល់ខែ។
- មិនទាន់មានការអនុវត្តនីតិវិធីសាស្ត្រតាម SOP of CoPCT ថ្មី សំរាប់ស្ត្រីធ្វើការនៅសេវាកំសាន្តនៅឡើយទេ។

## <u>**សំណូមពរ និងដំណោះស្រាយ**</u>

- ក្រុមអភិបាលបានណែនាំអោយអង្គការ RHAC ដែលជាដៃគូទាំងនោះ ចាប់ផ្តើមប្រើប្រាស់ទំរង់បញ្ជី PF ព្រោះទំរង់នេះមានសារសំខាន់ណាស់សំរាប់គ្រប់គ្រងស្ត្រីធ្វើការនៅសេវាកំសាន្តបានត្រឹមត្រូវ និងច្បាស់លាស់ អាចអោយអង្គការនិមួយតាមដានដឹងពិតប្រាកដអំពីការគ្របដណ្តប់នៃក្រុម គោលដៅដែលទៅប្រើប្រាស់សេវាថែទាំសុខភាពពិតប្រាកដបាន។

- មន្ត្រីអង្គការ RHAC សុំអោយថ្នាក់ជាតិផ្សព្វផ្សាយ SOP ថ្មី ដើម្បីរៀបចំរចនាសម្ពន្ធ័ការងារអោយបានច្បាស់លាស់ ងាយស្រួលដល់ការអនុវត្តន៏ការងារ ។
- ការបណ្តុះបណ្តាលមន្ត្រីមណ្ឌលសុខភាពដែលផ្តល់សេវាថែទាំជំងឺកាមរោគ ដើម្បីអោយមន្ត្រីទាំងនោះអាចធ្វើរោគវិនិច្ឆ័យ និងព្យាបាលជំងឺដោយប្រើប្រាស់ស្តេគូឡូម ។ ចំពោះការរៀបចំអោយមានគ្លីនិកសុខភាពគ្រួសារនៅក្រុងសែនមនោរម្យ ផ្នែកគ្រប់គ្រងព្យាបាលការបង្ករោគតាមការរួមភេទ និងប្រដាប់បន្តពូជ នឹងសុំការអនុញ្ញាតិអំពីឯកឧត្តមប្រធានមជ្ឈមណ្ឌលជាតិ ដើម្បីលើកផែនការបញ្ចូលទៅក្នុងគំរោងមូលនិធិសកលជុំទី ១១ នាពេលខាងមុខ ។
- សុំថ្នាក់ជាតិចុះអភិបាលកិច្ចអោយបានទៀងទាត់ ដើម្បីណែនាំនូវចំនុចខ្វះខាតនានា ។

ភ្នំពេញ, ថ្ងៃទី ១៣ ខែកញ្ញា ឆ្នាំ២០១០

បានឃើញ
ប្រធានមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺ
អេដស៍ សើស្បែក និងកាមរោគ

វេជ្ជ. អាន_ឈីវុន

អ្នកធ្វើរបាយការណ៍

វេជ្ជ. ផល សាណូ